**សេចក្តីប្រកាសព័ត៌មាន**

**នាយករដ្ឋមន្ត្រី នៃប្រទេសអូស្ត្រាលី**

**ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៨**

# សេចក្តីថ្លែងការណ៍រួម<br>នៃ រដ្ឋាភិបាលអូស្ត្រាលី ជប៉ុន និងសហរដ្ឋអាមេរិក<br>អំពី<br>ភាពជាដៃគូត្រីភាគីសម្រាប់វិនិយោគហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក

ថ្ងៃនេះ រដ្ឋាភិបាលប្រទេសអូស្ត្រាលី ជប៉ុន និងសហរដ្ឋអាមេរិក មានការប្តេជ្ញាចិត្តរួមគ្នា ក្នុងការថែរក្សា និងជំរុញ តំបន់ឥណ្ឌូប៉ាស៊ីហ្វិក ទៅជាតំបន់មួយប្រកបដោយសេរីភាព ការបើកចំហរ បរិយាប័ន្ន វិបុលភាព និងសន្តិសុខ ប្រកាសអំពីវឌ្ឍនភាពសំខាន់នៅក្នុងការប្តេជ្ញាចិត្តរួមគ្នាក្នុងការឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់។

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) និង សាជីវកម្មធនារ៉ាប់រង និងហិរញ្ញវត្ថុនាំចេញ (Efic) ធនាគារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JBIC) និងសាជីវកម្មវិនិយោគឯកជនក្រៅប្រទេសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក (OPIC) បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ត្រីភាគី (MOU) ដើម្បីធ្វើប្រតិបត្តិការ ភាពជាដៃគូត្រីភាគី សម្រាប់វិនិយោគហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ដែលបានប្រកាសនៅ ទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី៣០ ខែកក្កដា។ តាមរយៈ អនុស្សារណៈយោគយល់នេះ យើងមានបំណងធ្វើការរួមគ្នា ដើម្បីប្រមូល និងគាំទ្រឲ្យមានដើមទុនវិនិយោគវិស័យឯកជន ដើម្បីផ្តល់នូវគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្មីសំខាន់ៗ ពង្រឹងការតភ្ជាប់ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធថាមពល ព្រមទាំងសម្រេចនូវគោលដៅអភិវឌ្ឍរួមក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

ភាពជាដៃគូត្រីភាគីនេះ នឹងក្លាយជាកម្លាំងរួម នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ដោយផ្តល់នូវមធ្យោបាយថ្មីមួយ ដែលបណ្តាប្រទេសក្នុងតំបន់អាចសម្របសម្រួលដើម្បីជំរុញអាទិភាពហេដ្ឋារចនាសម្ព័ន្ធ។ ជាងនេះទៅទៀត ភាពជាដៃគូត្រីភាគី មានបំណងធ្វើការជាមួយរដ្ឋាភិបាលនៃប្រទេសក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ដើម្បីគាំទ្រ និងលើកទឹកចិត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែល

ស្របតាមស្តង់ដារអន្តរជាតិ និងគោលការណ៍អភិវឌ្ឍ ជាអាទ៍ ការបើកចំហរ តម្លាភាព និងនិរន្តភាព សារពើពន្ធ។ វិធីសាស្ត្រនេះ នឹងជួយបំពេញតម្រូវការពិតប្រាកដ ស្របពេលដែលអាចចៀសវាងនូវបន្ទុកបំណុលដែលគ្មាននិរន្តរភាពសម្រាប់ប្រជាជាតិក្នុងតំបន់។

នៅមុនកិច្ចប្រជុំកំពូល G២០ ឆ្នាំ២០១៩ នៅទីក្រុងអូសាកា រដ្ឋាភិបាលប្រទេសទាំងបី មានបំណងធ្វើការរួមគ្នាជាមួយសមាជិកដទៃទៀតនៃក្រុមប្រទេស G២០ ដើម្បីលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព។

ភាពជាដៃគូត្រីភាគី មានបំណងប្រឹក្សាជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសឥណ្ឌូប៉ាស៊ីហ្វិក រួមទាំងប្រទេសប៉ាពួញូហ្គីណេ ក្នុងការកំណត់គម្រោងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍ និងការផ្តល់ហិរញ្ញប្បទាន។ ដោយមានការពិគ្រោះយោបល់ជាមួយវិនិយោគិន និងក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធ ភាពជាដៃគូត្រីភាគី នឹងវាយតម្លៃអាទិភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការអភិវឌ្ឍរួម និងការផ្តល់ហិរញ្ញប្បទាន ព្រមទាំងពិចារណាការកំណត់អត្តសញ្ញាណនៃគម្រោងត្រីភាគី និងបេសកកម្មសិក្សាពីលទ្ធភាពនៃគម្រោងជាមុន តាមរយៈដំណើរការពិភាក្សាជាមួយរដ្ឋាភិបាលនៃប្រទេសក្នុងតំបន់ដើម្បីបង្កើតសំណើគម្រោងជាក់លាក់។

សេចក្តីប្រកាសទាំងនេះ រួមជាមួយអនុស្សរណៈនៃការយោគយល់ជាមូលដ្ឋាន តំណាងឱ្យការប្តេជ្ញាចិត្តថ្មីដ៏សំខាន់ របស់ប្រទេសអូស្ត្រាលី ជប៉ុន និងសហរដ្ឋអាមេរិកចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក តាមរយៈការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព និងផ្អែកតាមគោលការណ៍។